## យុត្តិកម្ម (justification)

វាជាទ្រឹស្តីមួយ ដែលត្រូវបានផ្តល់ន័យថា ជាការដោះសារ ដែលលុបចេញនូវកំហុសឆ្គងនៃបទល្មើស ចាត់សកម្មភាពខុសច្បាប់ទៅជាត្រឹមត្រូវវិញ។ ការការពារខ្លួនស្របច្បាប់ (self-defence) ជាឧទាហរណ៍មួយ។

ជាការពិត វាមានសារៈសំខាន់ក្នុងការបែងចែករវាងការដោះសារ (excuse) និង យុត្តិកម្ម។ ក្នុងករណី ការការពារស្របច្បាប់ ប្រសិនបើចារី ត្រូវបានរួចពីការទទួលខុសត្រូវ ដោយសារយុត្តិកម្ម អ្នកជួយ (accomplice) ក៏នឹងរួចផុតដែរ ដោយសារ យុត្តិកម្មលុបចោលនូវបទល្មើសដើម (principal offense)។

បន្ថែមលើការការពារស្របច្បាប់ បញ្ញាវន្ត ចាត់ការដាក់ទោសស្របច្បាប់ (order of court) ក៏ជាយុត្តិកម្មផងដែរ។ ស្រដៀងគ្នានេះដែរ គឺការគោរពបញ្ជាថ្នាក់លើ ដោយមិនដឹងថា បញ្ជានោះខុសច្បាប់ (superior order) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009,pp. 318-320)។